ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

កំណត់ហេតុកិច្ចប្រជុំថ្នាក់ដឹកនាំ
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែកុម្ភៈ ឆ្នាំ២០២៣

១. សេចក្តីផ្តើម

នៅថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៣:០០នាទីរសៀល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ម៉ូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តម លោកជំទាវអនុប្រធាន ឯកឧត្តមទីប្រឹក្សា នាយកខុទ្ទកាល័យ ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានទាំងបួន។

កិច្ចប្រជុំដំណើរការតាមរបៀបវារៈដូចខាងក្រោម ៖

១) មតិស្វាគមន៍ និងបើកកម្មវិធីរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
២) បទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
៣) បទបង្ហាញរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផណា** ស្តីពីការរៀបចំគម្រោងសំណើថវិកាមូលនិធិសកលឆ្នាំ២០២៤-២០២៦
៤) ការផ្តល់អនុសាសន៍បូកសរុបលទ្ធផល និងបិទកម្មវិធីដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. ដំណើរការ និងមតិពិភាក្សានៃកិច្ចប្រជុំ

១) មតិស្វាគមន៍ និងបើកកិច្ចប្រជុំរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី បានបើកកិច្ចប្រជុំ និងមានមតិស្វាគមន៍ដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំប្រចាំខែ ដោយផ្ទាល់ និងតាមប្រព័ន្ធនិមិត្ត ដែលជាឱកាសមួយក្នុងការពិនិត្យលើការងាររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា ការបើកកិច្ចប្រជុំ ការជួបជុំគ្នា ដើម្បីពិនិត្យអំពីវឌ្ឍនភាពការងារក្នុងខែកន្លងទៅ និងផែនការសកម្មភាពការងារដែលត្រូវធ្វើនាខែបន្ទាប់។

កិច្ចប្រជុំដំណើរការតាមរបៀបវារៈដូចខាងក្រោម ៖

១. របាយការណ៍ដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
២. បទបង្ហាញរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ថលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
៣. អនុសាសន៍បូកសរុបរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២) របាយការណ៍សកម្មភាពដោយ ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សេចក្តីរាយការណ៍ពីសកម្មភាព លទ្ធផលនានារបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែកុម្ភៈ ឆ្នាំ២០២៣។

នៅក្នុងបទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំ ជាពិសេសសកម្មភាពដ៏មមាញឹករបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តម លោកជំទាវអនុប្រធាន ក៏ដូចជាសកម្មភាព និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ សកម្មភាព និងព្រឹត្តិការណ៍សំខាន់ៗរួមមាន ៖

- ការអញ្ជើញរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ក្នុងពិធីសំណេះសំណាលជាមួយសិស្សនិទ្ទេស A ក្នុងការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ ហ៊ុន សែន**។
- អង្គវិបស្សនា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៣ នៅខេត្តបាត់ដំបង។
- ឯកឧត្តមទេសរដ្ឋមន្ត្រីអញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីជួបសំណេះសំណាលជាមួយ លោកគ្រូ អ្នកគ្រូ និងមន្ត្រីសុខាភិបាលនៃស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាព**ឯកឧត្តម ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ។
- បានរៀបចំកិច្ចប្រជុំក្រុមការងាររួមរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ស្តីពីការងារអេដស៍នៅប្រទេសកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

- ពិធីផ្សព្វផ្សាយអប់រំមេរោគអេដស៍ និងជំងឺអេដស៍ នៃទិវានៃក្តីស្រឡាញ់ ក្រោមប្រធានបទ "បង្ហាញសេចក្តីស្រឡាញ់របស់អ្នកតាមរយៈការបង្ការមេរោគអេដស៍" នៅទីធ្លាមុខអគារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- កិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀតថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពី «ការបញ្ចូលសេវាធ្វើតេស្តឈាម ព្យាបាលថែទាំអ្នកជំងឺអេដស៍ នៃវិស័យឯកជនក្នុងប្រព័ន្ធជាតិ»។
- ចូលរួមក្នុងសិក្ខាសាលា ស្តីពី "សុវត្ថិភាព និងការបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងវិស័យទេសចរណ៍" រៀបចំដោយក្រសួងទេសចរណ៍ នៅខេត្តក្រចេះ។
- កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពី «ការបញ្ចូលសេវាធ្វើតេស្តឈាម ព្យាបាលថែទាំអ្នកជំងឺអេដស៍ នៃវិស័យឯកជនក្នុងប្រព័ន្ធជាតិ» ក្រោមអធិតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមទេសរដ្ឋមន្ត្រី។
- កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី២ ដើម្បីពិនិត្យ និងពិភាក្សាលើប្រធានបទ "យុទ្ធវិធីជំរុញខ្លាំងក្លាការងារបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុម ប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា"។
- កិច្ចប្រជុំ ស្តីពីការពិនិត្យ "សេចក្តីព្រាងគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍ នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨" របស់ក្រុមលេខាធិការដ្ឋានក្រោមកិច្ចដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ោ ប៊ុនឡេង** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ការចុះពិនិត្យការធ្វើតេស្តរកមេរោគអេដស៍ដល់ក្រុមបុរសរួមភេទជាមួយបុរស (MSM) និងក្រុមបំប្លែងភេទ (TG) ដែលរៀបចំដោយក្រុមវេយន្តចល័តអង្គការខាណា (KHANA) នៅកោះពេជ្រ។ តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសបានរកឃើញករណីមេរោគអេដស៍ថ្មី និងមេរោគអេសដ៍ចាស់ប្រមាណជិត២០០០នាក់ (១៩១៧) ថ្មី ១២.៥% MSM ១៤០០ TG ៤៣៦ EW ២៥២។

ជាបញ្ហាប្រឈមឃើញថា MSM មិនចង់ប្រើស្រោមអនាម័យ ហើយការប្រើប្រាស់ស្រោមនៅមានកម្រិតទាប ក៏ដូចជាការជំរុញការប្រើប្រាស់ PrEP មិនទាន់បានល្អនៅឡើយ។

៣) បទបង្ហាញដោយឯកឧត្តមវេជ្ជ. ទា ផល្លា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម ទា ផល្លា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើបទបង្ហាញពីការរៀបចំគម្រោងសំណើរថវិការមូលនិធិសកល ឆ្នាំ២០២៤-២០២៦។

ការពិនិត្យមើលគម្រោងដែលធ្លាប់មានគឺ ៖

- តាមការពិនិត្យលើផែនការយុទ្ធសាស្ត្រជាតិរបស់ NAA និងផែនការយុទ្ធសាស្ត្រសុខាភិបាលរបស់ NCHADS/MoH គឺតួនាទីរបស់ NAA ធំ តែការទទួលបានថវិកា សម្រាប់អនុវត្តសកម្មភាពមានចំនួនតិចតួច។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបំពេញតួនាទីជាអ្នកដឹកនាំសម្របសម្រួលលើការងារឆ្លើយតបមេរោគអេដស៍ទូទាំងប្រទេស។

- ការសម្របសម្រួលនៅមិនទាន់បានល្អទេ ក្នុងការរៀបចំគម្រោងមូនិធិសកលថ្មី (Funding Request Application) ដោយបច្ចុប្បន្នខាងការងារបង្ការបានលើកថវិកាច្រើនហួសកម្រិត។
- បញ្ហាការសម្រេចបានគោលដៅ ៩៥ ទី១ បានតែ៨៤% នៅតែជាបញ្ហាចម្បង។
- ការចម្លងមេរោគអេដស៍ ក្នុងចំណោម MSM នៅមានកម្រិតខ្ពស់។
- ការកំណត់គោលដៅបង្ការការឆ្លងមេរោគអេដស៍មុនពេលប្រឈម PrEP ក្នុងក្រុម MSM គឺ ៩០០០០នាក់ តែបច្ចុប្បន្នបានចំនួន ៧០២១១នាក់ទេ (ត្រីមាសទី៤ ឆ្នាំ២០២២)។
- តាមការសិក្សារបស់ FHI360 នៅក្នុងចំណោមក្រុម MSM ប្រមាណ ៩០០០០នាក់ មាន៣៣% មិនដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍ទេ ហើយក្នុងនោះ៥០% បានយល់ថាខ្លួនមិនមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ទេ។
- ចំនួនពាក់កណ្តាលនៃការរួមភេទក្នុងចំណោម MSM អត់មានការប្រើស្រោមអនាម័យ។
- NCHADS មានទិសដៅឆ្ពោះលុបបំបាត់ការចម្លងមេរោគអេដស៍។
- ការខ្វះថវិកាក្នុងការជ្រើសរើសអ្នកចុះអប់រំផ្ទាល់ដល់ក្រុមគោលដៅ ដោយបច្ចុប្បន្នមានអ្នកចុះអប់រំផ្ទាល់ប្រមាណតែ ១៥០នាក់ ហើយម្នាក់ៗត្រូវមើលក្រុមគោលដៅ ៣០០នាក់។

៤) ការផ្តល់អនុសាសន៍ ចូកសរុបលទ្ធផល និងបិទកម្មវិធីដោយឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ថា បទបង្ហាញរបស់**ឯកឧត្តមវេជ្ជ. ទា ផលា** បានលើកឡើងពីកង្វល់របស់យើងនៅលើគោលដៅ ៩៥ទី១។ ចំនួនអ្នកឆ្លងមេរោគអេដស៍នៅតែមានច្រើន ដូច្នេះយើងត្រូវត្រូវខិតខំរកវិធីសាស្ត្រយ៉ាងណាដើម្បីឱ្យ KP មកធ្វើតេស្តឈាមឱ្យបានច្រើន។ ចំពោះក្តីបារម្ភណ៍របស់យើងគឺថា ប្រសិនបើនៅតែមានសភាពបែបហ្នឹងអាចមានឧបសគ្គក្នុងការសម្រេចបានការបញ្ចប់អេដស៍ នៅឆ្នាំ២០២៥។ យើងត្រូវតែបន្តការងារលើកសំណើគម្រោង FRA-2024-2026។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ចំនួន ១០ចំណុច ៖

១) បន្តចូលរួមតាក់តែង សំណើរសុំថវិកា (Funding Request) ដោយទាញឱ្យចំមុខសញ្ញាដែលយើងចង់បានគឺរឿងការសម្របសម្រួល បន្ថែមថវិកាលើការងារបង្ការ ដោយក្នុងនោះរដ្ឋាភិបាលដាក់ថវិកាចំនួន ៥លានដុល្លាដែរ។ **ឯកឧត្តមវេជ្ជ ទា ផលា** និង**ឯកឧត្តមវេជ្ជ រស់ សីលវ៉ាត់** ត្រូវទទួលខុសត្រូវលើកិច្ចការនេះ។

២) អគ្គលេខាធិការដ្ឋាន ត្រូវបន្តពិនិត្យ តាមដានការរៀបចំសកម្មភាព ថវិកាចំនួន ៨០លានរៀល ថវិកា ៦០លានរៀល ដែលបានផ្តល់ដល់រាជធានី ខេត្ត និងរកចម្លើយពីការស្នើសុំថវិកាចំនួន ៤០លានរៀលទៀតដែលត្រូវផ្តល់ដល់ខេត្តផ្សេងទៀត។

៣) អគ្គលេខាធិការដ្ឋាន ត្រូវបន្តសិក្សាជាមួយ NCHADS រកវិបមន្ត ដើម្បីជំរុញឱ្យវិស័យឯកជនចូលរួមធ្វើតេស្តរកមេរោគអេដស៍ និងធ្វើរបាយការណ៍មក NCHADS។

៤) បន្តការងារតាក់តែងគោលនយោបាយបញ្ចប់អេដស៍ នៅឆ្នាំ២០២៥ និងចីរភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២៣-២០២៨។

៥) បន្តតាមដានការងារប្រគល់បណ្ណ ប.ស.ស ដល់ស្ត្រីបម្រើសេវាកំសាន្តសប្បាយ។

៦) បន្តការតាមដានកម្មវិធីបង្ការមេរោគអេដស៍ក្នុងចំណោម MSM,TG, EW, PrEP តើមានបញ្ហាអ្វីខ្លះដែលត្រូវការដោះស្រាយ។

៧) បន្តតាមដានការអនុវត្តគោលនយោបាយស្រោមអនាម័យ ១០០% ជាពិសេសក្រុម MSM (ត្រូវរៀបចំប្រជុំជាមួយអ្នកចែកចាយស្រោមអនាម័យ)។

៨) **ឯកឧត្តមវេជ្ជ ទា ផល** ត្រូវរៀបចំបទបង្ហាញដល់ក្រុមមូនិធិសកលដោយផ្តោតលើការងារបង្កើនថវិកាលើសកម្មភាពបង្ការ ការងារសម្របសម្រួល ការងារពង្រឹងយន្តការជាតិ (Country System) ដោយមានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាអ្នកទទួលខុសត្រូវរួមលើការដឹកនាំលើការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍)។

៩) **ឯកឧត្តមវេជ្ជ ហោ ប៊ុនឡេង** ត្រូវរៀបចំបទបង្ហាញ ស្តីពីគោលនយោបាយបញ្ចប់អេដស៍ ឆ្នាំ២០២៥ ដល់ក្រុមគណៈប្រតិភូមូនិធិសកល។

១០) បន្តសិក្សា ស្តីពីការបង្កលក្ខណៈលើកទឹកចិត្តដល់ក្រុមប្រជាជនគន្លឹះឱ្យមកធ្វើតេស្តឈាមរកមេរោគអេដស៍។

ជាទីបញ្ចប់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានមានមតិសំណេះសំណាល បូកសរុបលទ្ធផលក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងប្រកាសបិទកម្មវិធីប្រជុំ។

អង្គប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង ៤:៣៤ នាទីល្ងាច នាថ្ងៃខែឆ្នាំដដែល។

ថ្ងៃសុក្រ ១២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣

បានពិនិត្យត្រឹមត្រូវ	អ្នកធ្វើកំណត់ហេតុ
អគ្គលេខាធិការ អ.ជ.ប.ជ.អ	
	វេជ្ជ. ប៉ែន សេរីវង្ស
បានឃើញ និងឯកភាព	
ប្រធានអង្គប្រជុំ	**បណ្ឌិត ឈឹម យិនដាវ៉ែត**
ទេសរដ្ឋមន្ត្រីប្រធាន អ.ជ.ប.ជ.អ	

អៀង-មូលី